# PeaceQuest ជាសង្ខេប

PeaceQuest បដិសេដក្នុងការទទួលអោយមានសង្គ្រាម អំពើហឹង្សា ការប្រកាន់ពូជសាសន៏ ការប្រកាន់ភេទ និងការកាបសង្កត់ ទោះបីក្នុងទំរង់ណាក៏ដោយ ។ PeaceQuest បដិសេធក្នុងទទួលនូវការពិតដែលថា សិទ្ធិក្នុងការរស់នៅដោយស្ងៀមស្ងាត់ និងដោយសេរីភាពផ្សេងៗ ត្រូវបានគំរាមគំហែង និងរំលោភបំពានជាសាកលនៅក្នុងមូលដ្ឋាននៃការរស់នៅប្រចាំថ្ងៃ ។ PeaceQuest ត្រូវបានបង្កើតឡើងដោយក្រុមយុវជន នៅក្នុងស្ថាប័នដែលមានគំនិតរួមមួយថា គឺសន្តិភាពដែលជួយលើកដំកើងនូវសេរីភាពក្នុងទំរង់ផ្សេងៗ ។ វាបដិសេធជាដាច់ខាតលើការរំលោភបំពានផ្សេងៗ ដែលត្រូវបានដាក់មកលើប្រជាពលរដ្ឋលើពិភពលោក ហើយវាអនុវត្តនូវ ការបដិសេធផ្សេងៗដោយផ្អែកលើចំនេះដឹង និងការតាំងចិត្ត ។

តាំងពីឆ្នាំ១៩៨៣មក PeaceQuest បានធ្វើបានសំរេចក្នុងការផ្លាស់ប្តូរការយល់ដឹងរបស់មនុស្សរាប់ពាន់នាក់ លើសមត្ថភាព និងចំនេះដឹងរបស់គេដោយផ្ទាល់ក្នុងការផ្លាស់ប្តូរសង្គម តាមរយៈការផ្តោះប្តូរផ្សេងៗ ការធ្វើសន្និសិទ្ធសិក្ខាសិលា វីកម្មវិធីអប់រំផ្សេងៗ ការសិក្សាដល់ទីកន្លែង និងការធ្វើទំនាក់ទំនងយ៉ាងសកម្ម ។

លើពីនេះទៀត ស្ថាប័ននេះបានឧទ្ទិសដល់ការបង្រៀន និងការលើកដំកើងអោយមានដំណោះស្រាយប្រកបដោយសន្តិវិធី ដោយជៀសវាងនូវការសងសឹក វីការប្រើហឹង្សា ។ ទង្វើនេះត្រូវបានចាត់ទុកថាជាជំរើសទីបី រវាងអកម្មភាព និងការអំពើហឹង្សាផ្សេងៗ ។

PeaceQuest លើកទឹកចិត្តគ្រប់យុវជានទាំងអស់ អោយប្រើនូវគុណប្រយោជន៏នៃអំណាច និងសមត្ថភាពរបស់ពួកគេដើម្បីលើកទឹកចិត្ត អ្នកការិយាធិបតេយ្យអោយមានការផ្ទេរអំណាចខ្លះៗរបស់ពួកគេ ។

លិទ្ធិប្រជាធិបតេយ្យ ជាមួយនឹងការដោះស្រាយទំនាស់ដោយសន្តិវិធី គឺជាការផ្តោតជាចំបងរបស់យើង ។ ភាពស្មោះត្រង់ដឹកនាំយើងថា មនុស្សកំពុងតែប្រើនូវសមត្ថភាព និងការប្តេជ្ញាចិត្តក្នុងការនាំអោយបាននូវពិភពលោកមួយប្រសើរជាងនេះ ។

រាល់អ្វីដែលយើងធ្វើ គឺការកាន់ភ្ជាប់នូវសហប្រត្តិបត្តិការ និងការរំលឹកដល់ស្ថាប័ន នៅក្នុងប្រទេសមួយចំនួន ដូចជា Israel, Palestine, Bosnia, Macedonia, Serbia, Moldavia និង Belarus ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើការទាក់ទងនឹងទំនាស់ថ្មី និងការអន់ថយនៃលិទ្ធិប្រជាធិបតេយ្យ ក្នុងសង្គម ស៊ុយ អែត ក៏មានសារៈសំខាន់ដូចគ្នាផងដែរ ។ សន្តិភាព មិនមែនមានន័យថា គឺការគ្មានសង្គ្រាមមួយមុខនោះទេ វាទាក់ទងនឹង យុត្តិធមិ និងការចូលរួមពីយើងទាំងអស់គ្នា ។